**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គោរពជូនកម្មវិធីកូនខ្មែរពិត

## តើខ្ញុំជាអ្នកណា

ពេលវេលាកន្លងផុតទៅជាច្រើនឆ្នាំណាស់មកហើយ តែអតីតកាលប្រៀបដូចជាស្រមោល ដែលនៅតែដើរ អន្ទោល តាមប្រាណ ទន្ទឹមនិងយើងជារហូតមកដល់បច្ចុប្បន្ននេះ ។

ប្រសិនបើយើងនិយាយពីភាពជោគជ័យនា ពេលបច្ចុប្បន្ន យើងក៏ត្រូវត្រឡប់ក្រោយដើម្បី អោយអារម្មណ៏នឹកឃើញនូវ ភាពល្វីងជូចត់ កំសត់កំរ និងការតស៊ូ ដែលមានតែកាឈឺចាប់ នៃអតីតកាល ។

តែទាំងអស់នេះវាក៏គឺជាឱសថ និង ជាកំលាំងចិត្តមួយបានជួយរុញច្រានអោយយើងគ្រប់គ្នាឈានឆ្ពោះមកដល់ពេលនេះ ។វាគួរអោយអាសូរណាស់មែនទេ?

ដែលមនុស្សម្នាក់មានជីវិតនិងគេដែរ តែមិនបានដឹងថាខ្លួនឯង ជាអ្នកណាមានប្រភពកំណើតមកពីទីណាអោយប្រាកដនោះ ។លោកអ្នកដឹងទេ ថាម្នាក់នោះជាអ្នកណា? ម្នាក់នោះគឺជា **ខ្ញុំ** ។

របបពិឃាតនៃរបប ៣ ឆ្នាំ ៨ ខែ និង ២០ថ្ងៃ វាបានបន្សល់ទុក នូវភាព និរាស ព្រាត់ប្រាស់ពិសេសបានបន្សល់ទុកនៅក្មេងកំព្រាជាច្រើននាក់ដែលរស់រងទុក្ខវេទនា លំបាកលំបិនដោយមកដល់ពេលនេះយើងមិនបានដឹងថាវាសនារបស់ពួកគេបានប្រែក្លាយទៅជាយ៉ាងណាអស់ហើយទេ? ហើយក្នុងចំណោមក្មេងកំព្រាទាំងនោះគឺមានរូប ខ្ញុំ ម្នាក់ដែរ ។ តែក្នុងចំណោមក្មេងកំព្រាទាំងអស់ ប្រហែលជាខ្ញុំមានសំណាងជាងពួកគេបន្តិច ។តើហេតុអីអ្នកដឹងទេ ? ពីព្រោះពេលដែលខ្ញុំបានដឹងក្តី ខ្ញុំបានយល់ ខ្ញុំបានស្គាល់ នូវអ្វី១ ដែលខ្ញុំបានឃើញនិងស្តាប់លឺ គឺខ្ញុំនៅមាន លោកតា លោកយាយ សំរាប់អោយខ្ញុំបានជ្រកកោនជាមួយ ។

មិត្តអ្នកស្តាប់ជ្រាបទេថាតើការរស់នៅរបស់អ្នកក្រីក្រវាមានរសជាតិបែបណា? អ្នកខ្លះលោកមិនបានដឹងទេ គឺមានតែអ្នកក្រដូចគ្នាទេទើបអាចយល់បាន ។ ខ្ញុំបានរស់នៅក្រោមវិមាននៃខ្ទមជរា ផ្ទះធ្លាយមួយដែលមានទំហំតូចរហូតមិនអាចពិព័ណនាបាន ទីនោះ គឺ គីឡូម៉ែត្រលេខ ៧ នៃខណ្ឌ ឬស្សីកែវ ។ ដែលនៅទីនោះសំបូរទៅដោយជនជាតិ ខ្មែរឥស្លាម រស់នៅ ។ ក្នុងខ្ទមជរាកំសត់ដ៏សែនតូចចង្អៀតរបស់ខ្ញុំគឺមិនមានសម្បត្តិ អ្វីសោះឡើយក្រៅអំពី ឆ្នាំងចាន ស្លាបព្រា ចាស់ៗ បន្តិចបន្តួច និងគ្រែរនាបឬស្សី តូចមួយ សំរាប់លោកតា លោកយាយ សំរាន្ត ។ ហើយមុខរបរសំរាប់ចិញ្ចឹមក្រពះរបស់ពួកយើងនៅពេលនោះគឺ ការប៉ះកង់តាមជញ្ជើមថ្នល់ ។

នៅរៀងរាល់ពេលរាត្រីដែល សព្វ មនុស្ស សត្វ ទាំងឡាយចូលនិទ្រា យ៉ាងមានសេចក្តី សុខ នោះ វាផ្ទុយស្រឡះពីរូបខ្ញុំ ពីព្រោះខ្ញុំ មិនមានសេចក្តីសុខដូចអ្នកទាំងនោះឡើយ ។ ខ្ញុំបានត្រឹមតែដេកក្បែរ ចង្ក្រានបាយ ដោយមានកន្ទេលចាស់ មួយកំណាត់សំរាប់ក្រាលជាទ្រនាប់ភ្ជាប់ទៅនិងដី មានខ្នើយច្រកសំឡីគ មួយនិងក្រម៉ាចាស់មួយសំរាប់គ្របដណ្តប់ខ្លួនអោយបាត់រងារ ។

អ្នកដឹងទេថាអារម្មណ៏របស់ខ្ញុំពេលនោះត្រូវការអ្វី? អ្វីដែលខ្ញុំ ត្រូវការ គឺពុក ម៉ែ ។ ខ្ញុំពិតជាចង់បរិយាយ អោយអស់នូវទំហំចិត្តដែលខ្ញុំត្រូវការនាពេលនោះណាស់ ប៉ុន្តែ ខ្ញុំមិនអាចទប់នូវទឹកភ្នែកនិង អារម្មណ៏ក្តុកក្តួលអួលណែន ពេលនេះបានឡើយ ។

ខ្ញុំនៅចងចាំបានថា បវេសនកាល ក្នុងឆ្នាំ១៩៨០ , ១៩៨១ ខ្ញុំមានវាសនាខ្ពស់ណាស់ដោយបានលោកយាយខំប្រឹងទាំងត្រដាបត្រដួស បញ្ជូនអោយខ្ញុំបានចូលសាលារៀន និងគេ ។ ខ្ញុំមានសំលៀកបំពាក់តែ បីរ សំរាប់ប៉ុណ្ណោះ ។មួយសំរាប់ ទុកសំរាប់ស្លៀកទៅសាលា និងពីរ សំរាប់ទៀត ទុកស្លៀកនៅផ្ទះ ។ វាគួអោយអាសូរនិងខ្លោចផ្សាណាស់សំរាប់រូបខ្ញុំ ។ នៅថ្ងៃចូលសាលាដំបូងខ្ញុំ ត្រូវបានលោកយាយ ជូនទៅសាលារៀន ។អ្នកដឹងទេ ថ្ងៃនោះខ្ញុំបានឃើញក្មេងៗដទៃ ទៀត គេមានពុកម៉ែ ជូនទៅសាលាមានសំលៀកបំពាក់ស្អាតៗនៅដៃមានកាន់នំសំរាប់ទុកទទួលទាន និងមានការលួងលោមពីឪពុកម្តាយដែលមើលទៅគួអោយមានសេចក្តីសុខណាស់ ។

អនិច្ចា អ៊ីរូបខ្ញុំ បាន ត្រឹមតែឈរមើលពួកគេដោយអារម្មណ៏ក្តុកក្តួលនិងក្រៀមក្រំព្រោះតែសេចក្តីត្រូវការស្រេកឃ្លាន និងចង់បាន ដូចជាគេដែរ ។ ជាងនេះទៅទៀត ពេលដែលខ្ញុំចូលថ្នាក់រៀនដំបូង លោកគ្រូបានសួរសិស្សទាំងអស់ម្នាក់ម្តង១ ពីឈ្មោះរបស់ ឪពុកម្តាយ និងបង ប្អូន ។ ពួកគេឆ្លើយ ប្រាប់លោកគ្រូដោយសប្បាយរីករាយគ្រប់គ្នា ។

ចំណែកខ្ញុំវិញបែជាភ័យហើយបានត្រឹមសម្រក់ទឹកភ្នែកនិងលើកដៃសំពះជំរាបលោកថាខ្ញុំគ្មានពួកគាត់ទេ ។ មិត្តក្នុងថ្នាក់បានមើលមកខ្ញុំ សួរខ្ញុំថា ហេតុអ្វី បានជាឯង អត់មានម៉ែ អត់មានពុក? ខ្ញុំគ្មានចំលើយសំរាប់ពួកគេសោះឡើយ ។ តើទេវតាពិតជាអយុត្តិធិមសំរាប់មនុស្សលោក ណាស់ មែនទេ?

លោកបានផ្តល់អោយអ្នកដ៏ទៃទៀតគ្រប់ យ៉ាង តែសំរាប់ក្មេងកំព្រាកំសត់ម្នាក់នេះលោកបែជាមើលរំលង តើខ្ញុំបានសាងអ្វីខុសពីជាតិមុនមែនទេ ទើបលោកទំលាក់កំហុសដាក់ខ្ញុំបែបនេះ?

ទេវតាលោកផ្តល់នូវជីវិតអោយខ្ញុំ តែលោកមិនបានផ្តល់អោយខ្ញុំបានស្គាល់ នូវមុខមាត់របស់លោក ពុក អ្នកម៉ែ ដែលបានផ្តល់ កំណើតអោយ ខ្ញុំទេ សូម្បីតែ រូបថត មួយសន្លឹក ក៏គ្មានបន្សល់ទុកសំរាប់ខ្ញុំដែរ ។

តើពួកគាត់មានរូបរាងយ៉ាងណា មុខមាត់ដូចម្ដេច? តើទឹកដោះម្ដាយដែលមានតំលៃមិនអាចកាត់ថ្លៃបាន សំរាប់អ្នករាល់គ្នា នោះតើវាមានរសជាតិ បែបណាទៅ? ជីវិតរបស់ខ្ញុំមិនដែលបានស្គាល់សូម្បីតែបន្តិចសោះឡើយ ។ គួរអោយសង្វេគណាស់ដែលក្មេងម្នាក់នេះ មិនធ្លាប់បាន ស្គាល់ សោះ នូវរាល់ការបីរត្រកង ថ្នាក់ថ្នម បបោសអង្អែល ក្រោមរង្វង់ដៃ ដ៏សែន កក់ក្ដៅ របស់ ពុក ម៉ែ ដូចអ្នករាល់គ្នា ។

ខ្ញុំគ្មាន ទេពុក ខ្ញុំគ្មាន ទេម៉ែ គ្មានទេបង គ្មានទេប្អូន ហើយខ្ញុំចង់ហៅពាក្យនេះដូចជាអ្នកគ្រប់គ្នាណាស់ ។ទេវតាលោកអើយខ្ញុំសូមអង្វរសូមអ្នកផ្ដល់អោយខ្ញុំផង ខ្ញុំពិតត្រូវការណាស់ ។

តែចំឡើយគឺជាតិនេះគ្មានទេសំរាប់រូបខ្ញុំ ។ ហើយប្រសិនបើខ្ញុំមាន ពុក មានម៉ែ មាន បង មាន ប្អូន ម៉្លេះ ជីវិតខ្ញុំពិតជាសប្បាយដូចអ្នករាល់គ្នាហើយ ខ្ញុំតែងតែស្រម័យថាខ្ញុំបានដេកក្បែរទ្រូងម៉ែ បានកា បីបម ថ្នាក់ថ្នមពីម៉ែ បានអោបថើបម៉ែ ហើយពុកនិងលើក បីរ ត្រកង ខ្ញុំឡើង ហើយ និង បន្លឺសំឡេងហៅខ្ញុំថាកូនសំលាញ់ ពុក កូនសំលាញ់ម៉ែ ពុក ម៉ែស្រលាញ់កូនណាស់កូនដឹងទេ? តែបន្ទាប់ពីកាស្រម័យគឺការសម្រក់ទឹកភ្នែកដេកអោបចង្រ្កានបាយដណ្ដប់ក្រម៉ារងាឯការតែម្នាក់ឯង ។ នេះហើយជាក្ដីស្រម័យរបស់កូនកំព្រា ។

តើក្នុងលោកនេះមានមនុស្សអភ័ព្វដូចខ្ញុំប៉ុន្មាននាក់ទៀត ឬក៏មានតែរូបខ្ញុំទេ?

ខ្ញុំសូមស្លេះការបរិយាយត្រឹមនេះសិនចុះ ពីព្រោះខ្ញុំមិនអាច ទប់នូវ ទឹកភ្នែកដែលកំពុងតែដណ្ដើមគ្នាហូរជ្រែក នូវផ្ទៃមុខរបស់ខ្ញុំបានទៀតទេ ។

ហើយជាចុងបញ្ចប់ខ្ញុំសូមសន្យាថា ខ្ញុំនិងសសេរនៅរឿង ពិត តាំងពី កុមារភាព រហូត បច្ចុប្បន្ន របស់ខ្ញុំ ក្នុង **កម្មវិធីកូនខ្មែរពិតនេះ** ។

ខ្ញុំសង្ឃឹមថាលិខិតនិងបានលឺតាមរលកសំលេងនៃវិទ្យុ 88 នេះ សូមអគុណទុកជាមុន ។

សូមគោរពជូនពរអោយអ្នកទាំងអស់គ្នាជួបប្រទះតែសេចក្ដីសុខជានិច្ចនិរន្ដរ៍ ។

**វគ្គទី១ នៃសំណេរ ខ្ញុំជាអ្នកណា**

ភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៨

**ពីខ្ញុំជាអ្នកណា**